ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

SOCIAL PROTECTION IN CAMBODIA

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

# សេចក្តីជូនដំណឹង

## ស្តីពី

## ការបើកផ្តល់ប្រាក់ឧបត្ថម្ភជូនបងប្អូនកម្មករនិយោជិតក្នុងវិស័យកាត់ដេរ និងទេសចរណ៍ ដែលត្រូវបានព្យួរកិច្ចសន្យាការងារស្របតាមស្មារតីនៃកញ្ចប់វិធានការរបស់រាជរដ្ឋាភិបាល (លើកទី៥២)

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ សូមជូនដំណឹងដល់បងប្អូនកម្មករនិយោជិតចំនួន ៦ ៣៥៦ នាក់ នៃរោងចក្រ សហគ្រាស ទាំង៣១ នៃវិស័យកាត់ដេរ និងវិស័យទេសចរណ៍ (ដូចមានភ្ជាប់នៅក្នុងឧបសម្ព័ន្ធ) ដែលទទួលបានការអនុញ្ញាតព្យួរកិច្ចសន្យាការងារស្របតាមស្មារតីជុំទី៣នៃកញ្ចប់វិធានការរបស់រាជរដ្ឋាភិបាលជ្រាបថា ធនាគារឯកទេសវីង នឹងផ្ញើសារអំពីការបើកប្រាក់ឧបត្ថម្ភរបស់រាជរដ្ឋាភិបាលទៅលេខទូរសព្ទ ដែលបងប្អូនបានផ្តល់មកឱ្យក្រសួងតាមរយៈរដ្ឋបាលរោងចក្រ សហគ្រាសនាពេលកន្លងមក។

ប្រាក់ឧបត្ថម្ភនេះនឹងត្រូវបើកផ្តល់ជាប្រាក់រៀល និងអាស្រ័យលើចំនួនថ្ងៃនៃការព្យួរកិច្ចសន្យាការងារ ក្នុងនោះចំនួនៈ

- ១២១ ៥០០រៀល (៣០ដុល្លារអាម៉េរិក) សម្រាប់ការព្យួរកិច្ចសន្យាការងាររយៈពេល ១១ថ្ងៃ ដល់ ២០ថ្ងៃ
- ១៦២ ០០០រៀល (៤០ដុល្លារអាម៉េរិក) សម្រាប់ការព្យួរកិច្ចសន្យាការងាររយៈពេលចាប់ពី ២១ថ្ងៃ ដល់ ១ខែ។ សូមបញ្ជាក់ថា សម្រាប់បងប្អូនដែលព្យួរកិច្ចសន្យាការងាររយៈពេល ២ខែ ប្រាក់ឧបត្ថម្ភនឹងត្រូវបើកជា ២លើក ដោយលើកទី២ នឹងបើកនៅថ្ងៃទី២៣ ខែមីនា ឆ្នាំ២០២១។

ក្រសួងសូមរំឭកថា ធនាគារឯកទេសវីង នឹងបង្វិលប្រាក់ឧបត្ថម្ភនេះជូនរាជរដ្ឋាភិបាលវិញ ប្រសិនជាបងប្អូនខកខានមិនបានទៅបើកប្រាក់ឧបត្ថម្ភនេះ ក្នុងរយៈពេល ១០ថ្ងៃ បន្ទាប់ពីទទួលបានសារតាមទូរសព្ទពីធនាគារឯកទេសវីង។ ដើម្បីបើកប្រាក់ឧបត្ថម្ភនេះ បងប្អូនត្រូវយកអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ និងទូរសព្ទដែលទទួលបានសារនោះទៅកាន់ភ្នាក់ងារវីងដែលនៅជិតបំផុត។ សូមបញ្ជាក់ថា បងប្អូនមិនតម្រូវឱ្យបង់ថ្លៃសេវាទៅភ្នាក់ងារវីងឡើយពេលបើកប្រាក់ឧបត្ថម្ភនេះ។

ក្នុងករណីបងប្អូនកម្មករនិយោជិត ដែលបម្រើការងារនៅរោងចក្រ សហគ្រាស ទាំង៣១ នេះ មិនបានទទួលសារទូរសព្ទពីធនាគារឯកទេសវីង នោះសូមបងប្អូនទំនាក់ទំនងសួរព័ត៌មានបន្ថែម ឬធ្វើបច្ចុប្បន្នភាពលេខទូរសព្ទរបស់ខ្លួន ទៅរដ្ឋបាលរោងចក្រ សហគ្រាសរបស់ខ្លួន។ ក្រសួងនឹងបន្តជូនដំណឹងដល់បងប្អូនកម្មកររោងចក្រ សហគ្រាសដទៃផ្សេងទៀតអំពីការបើកផ្តល់ប្រាក់ឧបត្ថម្ភនេះ។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូម សាធារណជន ជាពិសេសបងប្អូនកម្មករនិយោជិតជ្រាបជាព័ត៌មាន និងសូមរួសរាន់ទំនាក់ទំនងបើកប្រាក់ឧបត្ថម្ភនេះនៅតាមភ្នាក់ងារវីងនានាដែលនៅជិតបំផុតឱ្យបានទាន់ពេលវេលា។

ថ្ងៃ ព្រហស្បតិ៍ ៦កើត ខែ ផល្គុន ឆ្នាំជូត ទោស័ក ព.ស.២៥៦៤
រាជធានីភ្នំពេញ ថ្ងៃទី ១៨ ខែ មីនា ឆ្នាំ២០២១

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
គណៈកម្មការអនុវត្តវិធានការរាជរដ្ឋាភិបាល

ឧបសម្ព័ន្ធ នៃសេចក្តីជូនដំណឹងចុះថ្ងៃទី៤ ខែមីនា ឆ្នាំ២០២១

បញ្ជីឈ្មោះ រោងចក្រ សហគ្រាស ក្នុងវិស័យកាត់ដេរ និងវិស័យទេសចរណ៍
ចំនួន ៣១ ដែលទទួលបានប្រាក់ឧបត្ថម្ភរបស់រាជរដ្ឋាភិបាល

| ល.រ | ឈ្មោះរោងចក្រ សហគ្រាស | រាជធានី ខេត្ត |
|---|---|---|
| ក. វិស័យកាត់ដេរ | | 14 |
| 1 | ក្រុមហ៊ុន ខ្វាន់ទុម ខ្លូស៊ីង (ខេមបូឌា) លីមីតធីត | ភ្នំពេញ |
| 2 | ក្រុមហ៊ុន ខាយ & ខាយវើលដ៍ | ភ្នំពេញ |
| 3 | ក្រុមហ៊ុន យ៉ង់ ស៊ឹង | កណ្តាល |
| 4 | ក្រុមហ៊ុន អ៊ី ហ្គាមេន ខូអិលធីឌី | កណ្តាល |
| 5 | ក្រុមហ៊ុន ហ្សុងហ្គ័រយុនជីន (ខេមបូឌា) ហ្គាមេនខូអិល ធីឌី | កំពង់ស្ពឺ |
| 6 | ក្រុមហ៊ុន អ៊ែដ្យាយល៍ ស្វេតចឺ (ខេមបូឌា) ខូអិលធីឌី | កំពង់ស្ពឺ |
| 7 | ក្រុមហ៊ុន ផាតធេច(ខេមបូឌា)ឯ.ក | កំពង់ស្ពឺ |
| 8 | ក្រុមហ៊ុន វីនតាយ សកខ៍ មេនូហ្វេឈ័រ អិលធីឌី | តាកែវ |
| 9 | ក្រុមហ៊ុន ណាញ ស្កាយ ហ្គាម៉ិន ឯ.ក | តាកែវ |
| 10 | ក្រុមហ៊ុន ជាតាន់ អ៊ិនដាសស្ទ្រៀល ឯ ក ស្រុកព្រៃឈរ ខេត្តកំពង់ចាម | កំពង់ចាម |
| 11 | ក្រុមហ៊ុន អរិន មេនូហ្វេកឌឺរីង ( ខ្មែរ ) | ព្រៃវែង |
| 12 | ក្រុមហ៊ុន ថប ស៊ីលវើរ លីមីធីត | ព្រៃវែង |
| 13 | ក្រុមហ៊ុន ហ៊ែលសា សៅអ៊ិសអេស៊ា ខូអិលលធីឌី | ស្វាយរៀង |
| 14 | ក្រុមហ៊ុន អិម ជេ ប៊ែក (ខេមបូឌា) ខូអិលធីឌី | ព្រះសីហនុ |
| ខ. វិស័យទេសចរណ៍ | | 17 |
| 15 | ក្រុមហ៊ុន កាំបូឌីយ៉ាណា អ៊ិនវេស្តមេនធ៍ (ភ្នំពេញ) ភីធីអ៊ី អែលធីឌី | ភ្នំពេញ |
| 16 | ក្រុមហ៊ុន សិប្បករអង្គរ ភ្នំពេញ | ភ្នំពេញ |

| ល.រ | ឈ្មោះភោជនីយដ្ឋាន សណ្ឋាគារ | រាជធានី ខេត្ត |
|---|---|---|
| 17 | ក្រុមហ៊ុន ស្កាយ យីង ត្រាវែល & ធួរ | ភ្នំពេញ |
| 18 | ក្រុមហ៊ុន កូបេ យៃតែននីស រ៉េស្ទូរ៉ែន | សៀមរាប |
| 19 | សណ្ឋាគារសុខាល័យអង្គរ រីហ្សត និងស្ប៉ា | សៀមរាប |
| 20 | ក្រុមហ៊ុន សិប្បករអង្គរ | សៀមរាប |
| 21 | ក្រុមហ៊ុន វេសថឺរេន ខូឡិចហ្សិន | សៀមរាប |
| 22 | សណ្ឋាគារ អង្គរ ហូតែល គ្រុប(សណ្ឋាគារ អប្សរា ផាឡេស) | សៀមរាប |
| 23 | សណ្ឋាគារ សាឯមសៀមរាប | សៀមរាប |
| 24 | ក្រុមហ៊ុន ហ្គោថូន ត្រាវែល ស៊ីវីស | សៀមរាប |
| 25 | ក្រុមហ៊ុន កាឡាស ខម(ខេមបូឌា)ភីធីអ៊ីអិលធីឌី (សណ្ឋាគារ អង្គរ អេរ៉) | សៀមរាប |
| 26 | ក្រុមហ៊ុន ដំណាក់យៃភីថល ឯ.ក | សៀមរាប |
| 27 | សណ្ឋាគារគោព្រៃ | សៀមរាប |
| 28 | ក្រុមហ៊ុន តារាវង្សី អង្គរ ហូថេល | សៀមរាប |
| 29 | ផ្ទះសំណាក់ សាគូអង្គរ | សៀមរាប |
| 30 | សណ្ឋាគារសោមាទេវីអង្គររីសត & ស្ប៉ា | សៀមរាប |
| 31 | ក្រុមហ៊ុន អានឡុង អេហ្សេត អ៊ិនវេសមេន | សៀមរាប |